# សេចក្តីជូនដំណឹង
# ស្តីពី
# កាលបរិច្ឆេទកំណត់ទុក សម្រាប់ការបែងចែកភាគលាភប្រចាំឆ្នាំ២០២៥ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិក និងសាធារណជនទាំងអស់មេត្តាជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេច នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៦ របស់ធនាគារ អេស៊ីលីដា នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦ ភាគហ៊ុនិកបានអនុម័តការបែងចែកភាគលាភជាសាច់ប្រាក់ក្នុងចំនួន **៥៥៥ រៀល** ក្នុងមួយភាគហ៊ុន ដែលស្មើនឹង **២៤០,៤០៥,៤៧៥,៥៤៥ រៀល** ស្មើនឹង **២៩.៩៩%** នៃប្រាក់ចំណេញប្រចាំឆ្នាំ២០២៥ ដើម្បីផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ចំនួន **៨០១,៦៤១,៤៦២,000 រៀល** និងការរក្សាប្រាក់ចំណេញនៅសល់ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុករបស់ធនាគារ អេស៊ីលីដា ដែលនឹងត្រូវអនុម័តចុងក្រោយដោយនិយ័តករពាក់ព័ន្ធ។ ចំពោះកាលបរិច្ឆេទកំណត់ទុក សម្រាប់ប្រកាសបញ្ជីឈ្មោះភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ (កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ) គឺនៅ**ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦**។

**សម្គាល់៖**

១. ភាគហ៊ុនិកដែលលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៦** នឹងនៅតែមានសិទ្ធិទទួលបានភាគលាភ។

២. ភាគហ៊ុនិកដែលទិញមូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៦** នឹងមិនមានសិទ្ធិទទួលបានភាគលាភនេះទេ និង

៣. ភាគលាភនេះនឹងត្រូវបែងចែកជូនភាគហ៊ុនិក បន្ទាប់ពីទទួលបានការអនុម័តពីនិយ័តករពាក់ព័ន្ធ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP